មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក**

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៣

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គូសបញ្ជាក់អំពីក្តីព្រួយបារម្ភចំពោះលក្ខខណ្ឌការងាររបស់កម្មករកាត់ដេរនៅកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) នៅតែបន្តមានការព្រួយបារម្ភអំពីលក្ខខណ្ឌការងារក្នុងរោងចក្រកាត់ដេរនៅកម្ពុជា ដែលពុំទាន់មានសុវត្ថិភាព និងផាសុខភាពសម្រាប់កម្មករនៅឡើយ ហើយនេះក៏ជាការរំលោភបំពានទៅលើសិទ្ធិការងារជាមូលដ្ឋានរបស់កម្មករ។ ការព្រួយបារម្ភរបស់ ម.ស.ម.ក មានកាន់តែខ្លាំងក្លាឡើង នៅពេលមានតួលេខនាពេលថ្មីៗនេះ ដែលបានចុះផ្សាយពីចំនួនកម្មកររោងចក្រជាច្រើនដួលសន្លប់ក្នុងឆ្នាំ២០១២ តាមការរាយការណ៍ដោយកាសែត *ឌឹខេមបូឌា ដេលី* ចេញផ្សាយនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ ដែលមានចំណងជើងថា (*"ចំនួនកម្មកររោងចក្រដួលសន្លប់បានធ្លាក់ចុះក្នុងឆ្នាំ២០១២"*)។

នាយកដ្ឋានអធិការកិច្ចនិងកិច្ចការច្បាប់នៃក្រសួងការងារបានបញ្ជាក់ថា មានកម្មកររោងចក្រចំនួន ១៦៨៦នាក់ នៅរោងចក្រចំនួន២៤ បានដួលសន្លប់ក្នុងឆ្នាំ២០១២ ដែលតួលេខនេះបង្ហាញពីចំនួនទាបជាងឆ្នាំ២០១១ ដែលមានកម្មករសន្លប់ចំនួន ១៩៧៣នាក់ នៅក្នុងរោងចក្រចំនួនតែ១២ ប៉ុណ្ណោះ។ ក៏ប៉ុន្តែ ស្ថិតិនេះផ្ទុយពីតួលេខដែលបានផ្តល់ឲ្យដោយសហជីពសេរីកម្មករ ដែលអះអាងថា មានកម្មកររោងចក្រចំនួន ២១០៧ មកពីរោងចក្រ២៩ បានដួលសន្លប់ក្នុងឆ្នាំ២០១២។ ទោះបីជាតួលេខរបស់ក្រសួងត្រូវគេចាត់ទុកថាមានភាពត្រឹមត្រូវក៏ដោយ ហើយទោះជាចំនួនអ្នកដួលសន្លប់មានការថយចុះក៏ដោយ ក៏ចំនួនរោងចក្រដែលមានកម្មករដួលសន្លប់មានការកើនឡើងដែរ ហើយនេះជាការសបញ្ជាក់ថា បញ្ហានៃការដួលសន្លប់នេះតាមពិតទៅមានការរីករាលដាលកាន់តែច្រើនឡើង។ យ៉ាងណាក៏ដោយ ចំនួននេះគឺនៅតែជាចំនួនខ្ពស់ខ្លាំងណាស់ ហើយបញ្ហានេះ គួរតែជាគោលដៅសម្រាប់ រោងចក្រ ផ្លាកយីហោ អ្នកប្រើប្រាស់ សហជីព និងរដ្ឋាភិបាល ក្នុងការទទួលស្គាល់បញ្ហានេះ និងចាត់វិធានការណ៍ដើម្បីធានាថា ឧបទ្ទវហេតុបែបនេះ ពិតជាត្រូវបានកាត់បន្ថយបានច្រើនក្នុងឆ្នាំ២០១៣។ ម.ស.ម.ក ព្យាយាម ផ្តោតយកចិត្តទុកដាក់លើបញ្ហា អាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ និងប្រព័ន្ធខ្យល់ចេញចូល នៅកន្លែងធ្វើការ ក៏ដូចជាការចង់បានឲ្យមានការបញ្ឈប់ការធ្វើការងារបន្ថែមម៉ោងដោយបង្ខំ ដែលទាំងអស់នេះជាកត្តាដែលត្រូវការការពិនិត្យមើល ក្នុងទស្សនៈនៃការការពារសិទ្ធិសម្រាប់បុគ្គលគ្រប់រូប ចំពោះការទទួលបាន ការពេញចិត្តចំពោះលក្ខខណ្ឌការងារដែលមានភាពយុត្តិធម៌និងគួរឲ្យចូលចិត្ត។

**ជាការឆ្លើយតប លោក សុខ លាំង មន្ត្រីសម្របសម្រួលគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សមានមតិថា៖**

*"ការទទួលខុសត្រូវរបស់ធុរកិច្ចដើម្បីផ្តល់នូវលក្ខខណ្ឌការងារល្អគួរឲ្យពេញចិត្ត ជាប្រការដែលមានសារសំខាន់ខ្លាំងណាស់។ ការយកចិត្តទុកដាក់ដែលមានការកើនឡើងច្រើនពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិលើវិស័យកាត់ដេរនៅកម្ពុជា មានន័យថា បញ្ហានេះត្រូវតែដោះស្រាយជាបន្ទាន់។ ក្រុមហ៊ុនម៉ាកយីហោស្លាកសញ្ញាអន្តរជាតិដែលទិញទំនិញពីរោងចក្រក្នុងប្រទេសកម្ពុជា គួរតែស្វែងយល់ពីបញ្ហានេះ ហើយដាក់សម្ពាធទៅលើសហគ្រាសផលិត ឲ្យកែលម្អលក្ខខណ្ឌការងារឲ្យកាន់តែមានភាពប្រសើរឡើង។ សកម្មភាពបែបនេះ នឹងនាំមកនូវកិត្តិយសក្នុងចំណោម អតិថិជនរបស់ខ្លួន ព្រមទាំង ជួយកម្ពុជាឲ្យបានអភិវឌ្ឍក្នុងទិសដៅដ៏ត្រឹមត្រូវទៀតផង"*។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សុខ លាង តាមទូរសព្ទ +៨៥៥(០)១២ ៥៨៨ ០៨១ ឬអ៊ីម៉ែលsokleang@cchrcambodia.org ឬលោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមទូរសព្ទ៖ +៨៥៥ (០) ៩៩៦ ៧៨៨០ឬ អ៊ីម៉ែល៖ robert.finch@cchrcambodia.org**។

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព"។